**សុន្ទរកថាគណៈប្រតិភូមីយ៉ាន់ម៉ា**

**នៅក្នុងកិច្ចប្រជុំលើកទី ១១ នៃរដ្ឋភាគីនៃ**

**អនុសញ្ញាស្តីពីការហាមប្រាម ការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស**

**និងការបំផ្លាញគ្រាប់មីន**

**នៅភ្នំពេញ ប្រទេសកម្ពុជា**

លោកប្រធាន

សូមអរគុណចំពោះការផ្តល់វេទិកាដល់រូបខ្ញុំ។

ក្នុងឋានៈជាសមាជិកមួយនៃសមាជិកស្ថាបនិកនៃគណៈកម្មាធិការរំសាយសព្វាវុធប្រជាជាតិទាំង ១៨（ENDC） នៅពេលដែលគណៈកម្មាធិការនេះត្រូវបានបង្កើតជាលើកដំបូងនៅឆ្នាំ ១៩៦២ មីយ៉ាន់ម៉ាកំពុងចូលរួមយ៉ាងសកម្មនៅក្នុងវិស័យរំសាយសព្វាវុធ។ មីយ៉ាន់ម៉ាបាន និងកំពុងចូលរួមជាបន្តក្នុងការចរចារ និងចូលរួមក្នុងវេទិការំសាយសព្វាវុធពាក់ព័ន្ធនានា ចាប់តាំងពីពេលនោះមក។ មីយ៉ាន់ម៉ាគាំទ្រសេចក្តីព្រាងដំណោះស្រាយស្តីពី "ការរំសាយអាវុធនុយក្លេអ៊ែរ "ប្រចាំឆ្នាំ នៅក្នុងមហាសន្និបាតសហប្រជាជាតិ រដ្ឋសមាជិកជាច្រើននៃអង្គការសហប្រជាជាតិគាំទ្រសេចក្តីព្រាងដំណោះស្រាយ ក្នុងឋានៈជាសហអ្នកគាំទ្រ។

លោកប្រធាន

ការរីកសាយភាយនៃអាវុធនុយក្លេអ៊ែរគឺជាការគម្រាមកំហែងមួយចំពោះសន្តិភាព និងសន្តិសុខអន្តរជាតិ។ មីយ៉ាន់ម៉ាយល់ថាដើម្បីឱ្យការប្រើប្រាស់ថាមពលនុយក្លេអ៊ែរមានសន្តិភាព និងសុវត្ថិភាព ចាំបាច់ត្រូវសម្រេចឱ្យបាន នូវការរំសាយអាវុធនុយក្លេអ៊ែរ និងការមិនរីកសាយនៃអាវុធនុយក្លេអ៊ែរជាសាកល។ មីយ៉ាន់ម៉ាគឺជាប្រទេសគាំទ្រយ៉ាងខ្លាំងក្លា នូវការមិនរីកសាយនៃអាវុធនុយក្លេអ៊ែរ និងគាំទ្រឱ្យពិភពលោកគ្មានអាវុធនុយក្លេអ៊ែរ។ មីយ៉ាន់ម៉ាគឺជាភាគីមួយនៃសន្ធិសញ្ញា ស្តីពីការមិនរីកសាយនៃអាវុធនុយក្លេអ៊ែរ（NPT）ចាប់តាំងពីខែ ធ្នូ ឆ្នាំ ១៩៩២ មក និងបានចុះហត្ថលេខាលើ កិច្ចព្រមព្រៀងការពារ និងលើពិធីសារស្តីពីបរិមាណតិចតួច ដោយអនុលោមតាម NPT ជាមួយទីភ្នាក់ងារថាមពល អាតូមិកអន្តរជាតិ។

លោកប្រធាន

ក្នុងឋានៈជាសមាជិកមួយរបស់អាស៊ាន មីយ៉ានម៉ាក៏បានចូលជាសមាជិកនៃសន្ធិសញ្ញាស្តីពីតំបន់គ្មានអាវុធនុយក្លេអ៊ែរនៅអាស៊ីអគ្នេយ៍（ SEANWFZ）ដែលធានាមិនឱ្យតំបន់នេះមានអាវុធនុយក្លេអ៊ែរផងដែរ។ មីយ៉ាន់ម៉ាបានចុះហត្ថលេខាលើ

សន្ធិសញ្ញានេះនៅឆ្នាំ ១៩៩៥ ហើយសន្ធិសញ្ញានេះបានចូលជាធរមាននៅឆ្នាំ ១៩៩៧។ យើងយល់ថាការបង្កើតតំបន់គ្មានអាវុធនុយក្លេអ៊ែរគឺជាវិធានការមានប្រសិទ្ធភាពចំពោះការមិនរីកសាយអាវុធនុយក្លេអ៊ែរ ហើយត្រួសត្រាយផ្លូវ ដើម្បីបញ្ចប់ការរំសាយអាវុធនុយក្លេអ៊ែរ។ មីយ៉ាន់ម៉ាក៏បានចុះហត្ថលេខាលើសន្ធិសញ្ញាហាមប្រាមការសាកល្បងអាវុធនុយក្លេអ៊ែរ (CTBT) កាលពីខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ផងដែរ។ ការចូលរួមនៅក្នុងអនុសញ្ញាស្តីពីការរំសាយសព្វាវុធ សឱ្យឃើញការឧទ្ទិសរបស់មីយ៉ាន់ម៉ាចំពោះសន្តិភាព និងសន្តិសុខអន្តរជាតិ និងតំបន់។

លោកប្រធាន

ប្រទេសមីយ៉ាន់ម៉ាបានបញ្ជាក់រួចហើយនូវជំហររបស់ខ្លួនអំពីការរំសាយអាវុធនុយក្លេអ៊ែរ និងការមិនរីកសាយអាវុធនុយក្លេ-អ៊ែរ ព្រមទាំងការប្រឆាំងរបស់ខ្លួនចំពោះការប្រើប្រាស់ ការអភិវឌ្ឍ និងការផ្ទេរអាវុធមហាប្រល័យទាំងនេះ ទោះបីនៅក្នុងកាលៈទេសៈណាក្តី។ មីយ៉ាន់ម៉ាបានចុះហត្ថលេខាលើសន្ធិសញ្ញាស្តីពីការហាមប្រាមការសាកល្បងអាវុធនុយក្លេអ៊ែរ នៅក្នុងបរិយាកាស នៅក្នុងលំហអាកាសខាងក្រៅ និងនៅក្រោមទឹក កាលពីថ្ងៃ ទី ១៤ ខែ សីហា ឆ្នាំ ១៩៦៣ និងបានផ្តល់សច្ចាប័នចំពោះសន្ធិសញ្ញានេះកាលពីថ្ងៃ ទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៦៣។ ជាងនេះទៅទៀត មីយ៉ាន់ម៉ាបានចុះហត្ថលេខាលើសន្ធិសញ្ញាស្តីពីគោលការណ៍គ្រប់គ្រងសកម្មភាពរបស់រដ្ឋនានាក្នុងការរុករក និងប្រើប្រាស់លំហខាងក្រៅ រាប់ទាំងព្រះច័ន្ទ និងភពក្នុងលំហអាកាសដទៃទៀត ដែលហៅថា "សន្ធិសញ្ញាស្តីពីលំហអាកាសខាងក្រៅ " កាលពីថ្ងៃ ទី ២២ ខែ ឧសភា ឆ្នាំ ១៩៦៧។ មីយ៉ាន់ម៉ាបានផ្តល់សច្ចាប័នចំពោះសន្ធិសញ្ញានេះកាលពីថ្ងៃ ទី ១៨ ខែ មីនា ឆ្នាំ ១៩៧០។

ក្រៅពីនេះ មីយ៉ាន់ម៉ាបានចូលរួមក្នុងកិច្ចប្រឹងប្រែងហាមប្រាមអាវុធមហាប្រល័យ។ មីយ៉ាន់ម៉ាបានចុះហត្ថលេខាលើសន្ធិសញ្ញាស្តីពីការហាមឃាត់ការដាក់អាវុធនុយក្លេអ៊ែរ និងអាវុធមហាប្រល័យដទៃទៀតនៅក្នុងបាតសមុទ្ទ បាតមហាសមុទ្ទ និងក្រោមដី ឬសន្ធិសញ្ញាស្តីពីបាតសមុទ្ទ កាលពីថ្ងៃ ទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៧១។ អនុសញ្ញាស្តីពីការហាមឃាត់ការអភិវឌ្ឍ ការផលិត និងការរក្សាទុកអាវុធមេរោគ (ជីវសាស្ត្រ) និងអាវុធជាតិពុល និងស្តីពីការបំផ្លាញអាវុធទាំងនោះ ឬអនុសញ្ញាស្តីពីអាវុធជីវសាស្ត្រ កាលពីថ្ងៃ ទី ១០ ខែ មេសា ឆ្នាំ ១៩៧២ និងអនុសញ្ញាស្តីពីការហាមឃាត់ការអភិវឌ្ឍ ការផលិត ការរក្សាទុក និងការប្រើអាវុធគីមី និងការបំផ្លាញអាវុធទាំងនេះ ឬអនុសញ្ញាស្តីពីអាវុធគីមី កាលពីថ្ងៃ ទី ១៤ ខែ មករា ឆ្នាំ ១៩៩៣។

លោកប្រធាន

ចំពោះគ្រាប់មីនប្រឆាំងមនុស្សវិញ មីយ៉ាន់ម៉ាយល់ថាប្រសិនបើគ្រាប់មីនទាំងនេះត្រូវបានប្រើដោយឥតរើសមុខពីសំណាក់អ្នកបះបោរ ឬក្រុមប្រដាប់អាវុធក្រៅក្របខណ្ឌច្បាប់របស់ប្រទេស សកម្មភាពនេះនឹងបណ្តាលឱ្យមានការស្លាប់ និងរបួសចំពោះជនស៊ីវិល រួមមាន ស្ត្រី និងកុមារ។ ហេតុនេះ ការផ្ទេរ និងការនាំចេញគ្រាប់មីនប្រឆាំង មនុស្សរួមចំណែកដល់ការរីកសាយនៃបរិធានទាំងនេះ ហើយបង្កើនឱកាសប្រើប្រាស់ដោយមិនរើសមុខ។ មីយ៉ាន់ម៉ាប្រកាន់ គំនិតថា

ការពិចារណាដោយប្រុងប្រយ័ត្នចំពោះបញ្ហានេះ ជាវិធីសមស្របបំផុតក្នុងការដោះស្រាយបញ្ហានេះ។ ជាមួយគ្នានេះដែរមីយ៉ាន់ម៉ាយល់ថាសិទ្ធិត្រឹមត្រូវតាមច្បាប់របស់រដ្ឋនីមួយៗក្នុងការស្វ័យការពារបញ្ហាសន្តិសុខជាតិរបស់ខ្លួន ចាំបាច់ត្រូវទទួលស្គាល់ និងគោរព ក្នុងការដោះស្រាយបញ្ហានេះ។

លោកប្រធាន

ខ្ញុំសូមសំដែងនូវកតវេទិតាជាថ្មីម្តងទៀតចំពោះលោកប្រធាន និងចំពោះស្ថាប័នរៀបចំការចាត់ចែងសន្និសីទនេះ។

សូមអរគុណលោកប្រធាន